ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ:..០០៧.......សហវ.....

រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២

# សារាចរណែនាំ
# ស្តីពី
# ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣

## I. សេចក្តីផ្តើម

១- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២។ ដើម្បីអនុវត្តច្បាប់នេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ២៧៥ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ និងអនុក្រឹត្យលេខ២៧៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។ ផ្អែកលើមូលដ្ឋាននៃច្បាប់ និងអនុក្រឹត្យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ១០១៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ និងប្រកាសលេខ១០១៨ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។ ដើម្បីឲ្យការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ មានដំណើរការប្រកបដោយភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាពខ្ពស់ និងសម្រេចបានតាមគោលដៅ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំលើការអនុវត្តថវិកាថ្នាក់ជាតិសម្រាប់ឆ្នាំ២០១៣ ដែលមានតាមលំដាប់លំដោយដូចតទៅ៖

*២-ថវិកាឆ្នាំ២០១៣នេះ គឺពិតជាឧបករណ៍គោលនយោបាយដ៏មានសារៈសំខាន់បំផុតដើម្បីអនុញ្ញាតឲ្យរាជរដ្ឋាភិបាលបន្តអនុវត្តបញ្ចប់នូវ* **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២** *សំដៅឈានទៅសម្រេចឲ្យបាននូវ* **របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច** *នៃ* **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤** *។ ជាពិសេស ដើម្បីបន្តរក្សាស្ថិរភាពនយោបាយបន្តពង្រឹង និងពង្រីកការអនុវត្តលទ្ធិប្រជាធិបតេយ្យ បន្តរក្សាឲ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងធានាបាននូវភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងឈានទៅសម្រេចឲ្យបាននូវគោលនយោបាយគ្រឹះខាងសេដ្ឋកិច្ចគឺ "ការធានាឲ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពក្នុងរយៈពេល*

ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

*រឹងមានអត្រាខ្ពស់ប្រមាណ៧%ក្នុងមួយឆ្នាំ នៅលើមូលដ្ឋានទូលាយជាងមុន និងមានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍អត្រាអតិផរណាទាបក្នុងកម្រិតតួលេខមួយខ្ទង់ អត្រាប្តូរប្រាក់មានស្ថិរភាព និងមានកំណើនទុនបម្រុងជាប្រចាំ"និង "ការជានាសម្រេចឲ្យបាន នូវការកាត់បន្ថយអត្រានៃភាពក្រីក្រឲ្យបានលើស១%ក្នុងមួយឆ្នាំ និងការជានាកែលម្អសូចនាករសំខាន់ៗ ក្នុងវិស័យសង្គមកិច្ច ជាពិសេសក្នុងវិស័យអប់រំ សុខាភិបាល និងសមភាពយេនឌ័រ" ព្រមទាំងឈានទៅសម្រេចបាននូវគោលដៅសហស្សវត្សរ៍កម្ពុជាទាំង៩។* ចរិកានេះ ក៏បានឆ្លុះបញ្ចាំងឲ្យឃើញផងដែរពីការខិតខំប្រឹងប្រែង និងពុះពាររបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តកម្មវិធីអភិវឌ្ឍ និងកំណែទម្រង់លើគ្រប់វិស័យដែលកាន់តែស៊ីជម្រៅដូចជាកម្មវិធីអភិវឌ្ឍវិស័យឯកជន និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ កំណែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាល កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យ កំណែទម្រង់ការគ្រប់គ្រងដីធ្លី កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ព្រមទាំងការបង្កើនអភិបាលកិច្ចល្អ និងការបង្កើនការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីពង្រឹង និងពង្រីកមូលដ្ឋានសេដ្ឋកិច្ចឲ្យកាន់តែធំទូលាយ និងរឹងមាំ ព្រមទាំងដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពសេវាសាធារណៈក្នុងការបម្រើប្រជាពលរដ្ឋឲ្យកាន់តែប្រសើរឡើងថែមទៀត។

៣-*ផ្អែកលើមូលដ្ឋាននៃ* **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២** *និង* **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣** *ជាពិសេស ដើម្បីបម្រើឲ្យការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយអាទិភាពតាមវិស័យនិងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាលក្នុងការសម្រេចឲ្យបានតាមគោលដៅនៃ***របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច** *នៃ* **កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤** *ថវិកាឆ្នាំ២០១៣ មានគោលដៅសំខាន់ៗដូចតទៅ៖*

- បន្តអនុវត្តគោលបំណងគោលនយោបាយ កម្មវិធី យុទ្ធសាស្ត្រ និងបណ្តាសកម្មភាពការងារអាទិភាពតាមវិស័យ ពិសេសបន្តជំរុញការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ព្រមជាមួយនឹងកសិផលឯទៀតដូចជាកៅស៊ូនិងដំឡូងមី បន្តកសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ពិសេសស្តារហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលបានខូចខាតដោយទឹកជំនន់ឆ្នាំ២០១១ បន្តពង្រឹងនិងពង្រីកផ្នែកឧស្សាហកម្មកាត់ដេរនិងផ្នែកសេវាកម្មទេសចរណ៍ ជាមួយការខិតខំប្រឹងប្រែងពិពិធកម្មសេដ្ឋកិច្ចឲ្យកម្ពុជាក្លាយជាចំណែកនៃការផ្គត់ផ្គង់បំណែកឧស្សាហកម្មនៃផលិតផលលើសកលលោក ព្រមទាំងបន្តជំរុញការអភិវឌ្ឍវិស័យឯកជន ធនាគារ និងទីផ្សារហិរញ្ញវត្ថុ។
- បន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចគាំទ្រកំណើន និងកម្មវិធីវិនិយោគសាធារណៈរំកិល៣ឆ្នាំ២០១៣-២០១៥ ដើម្បីរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងជំរុញកំណើនប្រកបដោយចីរភាព។
- បន្តផ្តល់អាទិភាពដល់ការបង្កើន និងលើកកម្ពស់គុណភាពសេវាកម្មនៅក្នុងវិស័យសង្គមកិច្ច ជាពិសេស វិស័យអប់រំ សុខាភិបាល ការកសាងធនធានមនុស្ស និងសំណាញ់សុវត្ថិភាពសង្គម រួមទាំងការបន្តអនុវត្តគោលនយោបាយផ្តល់ដីសម្បទានសង្គមកិច្ចដល់គ្រួសារអតីតកងកម្លាំងប្រដាប់អាវុធ និងការបន្តជំរុញការអនុវត្តសកម្មភាពថ្មីលើគោលនយោបាយចាស់នៃកំណែទម្រង់ការគ្រប់គ្រងដីធ្លី។

- ធានាដល់ការរៀបចំការបោះឆ្នោតតំណាងរាស្ត្រ និងការបន្តជំរុញការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីបន្តពង្រឹង និងពង្រីកការអនុវត្តលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅកម្ពុជា។
- ធានាបម្រើឲ្យការបន្តសកម្មភាពកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលលើគ្រប់ផ្នែក រួមមាន កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កំណែទម្រង់ការគ្រប់គ្រងដីធ្លី កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យ និងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ដើម្បីបន្តពង្រឹងអភិបាលកិច្ចល្អ និងការបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

៤-ទន្ទឹមនឹងនេះ: ដើម្បីឲ្យការអនុវត្តគោលនយោបាយ និងកម្មវិធីសកម្មភាពជាអាទិភាពរបស់រាជរដ្ឋាភិបាលដូចបានគូសបញ្ជាក់ខាងលើសម្រេចបានជោគជ័យប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ ពិសេសក្នុងស្ថានភាពដែលសេដ្ឋកិច្ចពិភពលោកនៅមានហានិភ័យខ្ពស់នៅឡើយ រាជរដ្ឋាភិបាលនឹងបន្តជំរុញការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព រាល់ក្របខ័ណ្ឌច្បាប់ បទបញ្ញា និងវិធានការទាំងឡាយដែលមានស្រាប់ ព្រមទាំងបង្កើនការអប្បមាទជាប្រចាំ ដើម្បីដាក់ចេញនូវគោលនយោបាយ និងវិធានការដាក់ស្តែងបន្ថែមទៀតដែលមានលក្ខណៈជាប្រព័ន្ធ មានភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាព ព្រមទាំងទាន់ពេលវេលា សំដៅពង្រឹងសមិទ្ធិផលជាសន្តិភាព ឯកភាពទឹកដី សន្តិសុខ ធានាបានស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងធានាបាននូវការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុ ការគ្រប់គ្រងអតិផរណា ការបង្កើតបាននូវបរិស្ថានកាន់តែអនុគ្រោះសម្រាប់សកម្មភាពសេដ្ឋកិច្ច និងធុរកិច្ចជាមួយនឹងការពង្រឹងនិងពង្រីកនូវប្រព័ន្ធសុវត្ថិភាពសង្គមជូនដល់ប្រជាពលរដ្ឋ។

## II. លទ្ធផល និងវិធានការក្នុងការអនុវត្តថវិកាឆ្នាំ២០១៣

### ក- ការអនុវត្តការប្រមូលចំណូល

៥-ដើម្បីឲ្យការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣សម្រេចបានជោគជ័យ ជាពិសេស ដើម្បីឲ្យការអនុវត្តចំណូលសម្រេចបានតាមការគ្រោងទុក គឺដើម្បីឲ្យការប្រមូលចំណូលថវិការដ្ឋសរុបសម្រេចបានតាមគោលដៅ១២ ៤២៧ ៤៨៨លានរៀលកើន១២%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១២ គឺស្មើនឹង១៩,៦៥%នៃផ.ស.ស.។ ដើម្បីសម្រេចបានតាមគោលដៅនេះ រាជរដ្ឋាភិបាលត្រូវបង្កើនការប្រមូលចំណូល (១)ចំណូលក្នុងស្រុកថវិការដ្ឋនឹងប្រមូលឲ្យបាន៩ ០៥៩ ៤៦៧លានរៀលកើន១៧,៥%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១២ គឺស្មើនឹង១៤,៣៣%នៃផ.ស.ស. ដែលក្នុងនោះ ចំណូលចរន្តថវិការដ្ឋមាន៨ ៩០៥ ៤៦៧លានរៀលកើន១៦,៧% ស្មើនឹង១៤,០៨%នៃផ.ស.ស.(ចំណូលសារពើពន្ធថវិការដ្ឋមាន៧ ៧២៩ ៨៤០លានរៀលកើន១៧,៣% ស្មើនឹង១២,២២%នៃផ.ស.ស. និងចំណូលមិនមែនសារពើពន្ធថវិការដ្ឋមាន១ ១៧៥ ៦២៦លានរៀលកើន១២,៨% ស្មើនឹង១,៨៦%នៃផ.ស.ស.) និងចំណូលមូលធនក្នុងប្រទេសមាន៨២ ០០០លានរៀលកើន២,៥% ស្មើនឹង០,១៣%នៃផ.ស.ស. និង

(២)ចំណូលមូលធនក្រៅប្រទេសនឹងកៀរគរឲ្យបាន៣ ៣៦៨ ០២១លានរៀលថយចុះ០,៤%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១២ គឺស្មើនឹង៥,៣៣%នៃផ.ស.ស. ដែលក្នុងនោះ ចំណូលមូលនិធិទ្រទ្រង់ថវិកាមាន២២២ ០២១លានរៀលថយចុះ៥៧,៣% ស្មើនឹង០,៣៥%នៃផ.ស.ស. និងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសមាន៣ ១៤៦ ០០០លានរៀលកើន១០% ស្មើនឹង៤,៩៧%នៃផ.ស.ស.។

**៦**- ថវិកាឆ្នាំ២០១៣ បានឆ្លុះបញ្ចាំងពីកំណើនចំណូលក្នុងស្រុកថវិការដ្ឋប្រមាណ១៦,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១២ ដែលក្នុងនោះ ចំណូលក្នុងស្រុកជាថវិកាថ្នាក់ជាតិមាន៨ ៥៥៥ ៧៧៨លានរៀលកើន១៥,៩%ស្មើនឹង១៣,៥៣%នៃផ.ស.ស. និងជាថវិការាជធានី ខេត្តមាន៤៣១ ៩៣៥លានរៀលកើន៣០% ស្មើនឹង០,៦៨%នៃផ.ស.ស.។ ដើម្បីសម្រេចបានតាមគោលដៅនេះ គឺ(១) ចំណូលចរន្តថវិកាថ្នាក់ជាតិនឹងប្រមូលឲ្យបាន៨ ៤៧៣ ៧៧៨លានរៀលកើន១៦,១%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១២ ស្មើនឹង១៣,៤%នៃផ.ស.ស. ដែលក្នុងនោះ ចំណូលសារពើពន្ធថ្នាក់ជាតិមាន៧ ៣២១ ១១៤លានរៀលកើន១៦,៦% ស្មើនឹង១១,៥៨%នៃផ.ស.ស. (ចំណូលគយនិងរដ្ឋាករមាន៤ ០៦៥ ០០០លានរៀលកើន១៨,១% ស្មើនឹង៦,៤៣%នៃផ.ស.ស. ចំណូលពន្ធដារមាន៣ ០៥២ ៥៨១លានរៀលកើន១៦% ស្មើនឹង៤,៨៣%នៃផ.ស.ស. និងចំណូលសារពើពន្ធថ្នាក់ជាតិផ្សេងៗទៀតមាន២០៣ ៥៣៣លានរៀលថយចុះ១,៩% ស្មើនឹង០,៣២%នៃផ.ស.ស.) និងចំណូលមិនមែនសារពើពន្ធថ្នាក់ជាតិមាន១ ១៥២ ៦៦៤លានរៀលកើន១៣% ស្មើនឹង១,៨២%នៃផ.ស.ស. និង(២) ចំណូលចរន្តរាជធានី ខេត្តនឹងប្រមូលឲ្យបាន៤៣១ ៩៣៥លានរៀលកើន៣០% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១២ ស្មើនឹង០,៦៨%នៃផ.ស.ស. ដែលក្នុងនោះ ចំណូលសារពើពន្ធរាជធានី ខេត្តមាន៤០៨ ៧២៧លានរៀលកើន៣១,៨% ស្មើនឹង០,៦៥%នៃផ.ស.ស. និងចំណូលមិនមែនសារពើពន្ធរាជធានី ខេត្តមាន២៣ ២០៨លានរៀលកើន៥,៧% ស្មើនឹង០,០៤%នៃផ.ស.ស.។

**៧**- ដើម្បីសម្រេចបានតាមគោលដៅខាងលើ អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវរៀបចំអនុវត្តនិងតាមដានជាប្រចាំនូវកម្មវិធីប្រមូលចំណូលសារពើពន្ធប្រចាំត្រីមាសដែលមានការបែងចែកលម្អិតទៅតាមខែ។ បើគិតជាមធ្យមភាគប្រចាំខែ អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ចប្រមូលចំណូលពន្ធដែលជាចំណូលថវិកាថ្នាក់ជាតិឲ្យបានជាមធ្យម២៥៤ ៣៨១លានរៀលក្នុងមួយខែ។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាមានភារកិច្ចប្រមូលចំណូលពន្ធ និងអាករដែលជាចំណូលថវិកាថ្នាក់ជាតិឲ្យបានជាមធ្យម៣៣៨ ៧៥០លានរៀលក្នុងមួយខែ និងចំណូលសារពើពន្ធផ្សេងៗទៀតទាំងថ្នាក់ជាតិនិងរាជធានី ខេត្តត្រូវប្រមូលឲ្យបានជាមធ្យម៥១ ០២១លានរៀលក្នុងមួយខែ ទោះជាការប្រមូលជាក់ស្តែងអាចមានកម្រិតខ្ពស់ឬទាបជាងការគ្រោងទុកបន្តិចបន្តួចទៅតាមស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក៏ដោយ។ ទន្ទឹមនឹងនេះ កម្មវិធីប្រមូលចំណូលនេះ ត្រូវមានផែនការសកម្មភាពអនុវត្តលម្អិត និងទៅតាមប្រភេទនិងមាតិកាចំណូលនីមួយៗ ហើយប្រគល់ឲ្យតាមសាខាទីស្នាក់ការឬ/និងមន្ត្រីដែលមានភារកិច្ច និងការទទួលខុសត្រូវដោយផ្ទាល់ក្នុងការអនុវត្ត។

**៨**- ដើម្បីឲ្យការប្រមូលចំណូលមិនមែនសារពើពន្ធឆ្នាំ២០១៣នេះ សម្រេចបានតាមគោលដៅ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរបស់ខ្លួននៅតាមរាជធានី ខេត្ត ត្រូវរៀបចំកម្មវិធីប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំត្រីមាសដែលមានការបែងចែកលម្អិតតាមខែ ដោយផ្អែកលើកិច្ចសន្យានៃការជួល

ទ្រព្យសម្បត្តិរដ្ឋ កិច្ចសន្យាសម្បទាននានា ចំណូលពីសេវាបង់ថ្លៃ សកម្មភាពអាជីវកម្ម និងសង្វាក់នៃការប្រមូលចំណូលកន្លងមក ព្រមទាំងដាក់ផែនការសកម្មភាព និងវិធានការអនុវត្តលម្អិត និងទៅតាមប្រភេទ និងមាតិកាចំណូលនីមួយៗ ហើយប្រគល់ទៅឲ្យអង្គភាពក្រោមឱវាទនៅរដ្ឋបាលកណ្តាល និងនៅរាជធានី ខេត្ត ដែលមានភារកិច្ច និងការទទួលខុសត្រូវដោយផ្ទាល់ក្នុងការអនុវត្ត។ អង្គភាពប្រមូលចំណូលត្រូវធ្វើការតាមដាន និងជំរុញជាប្រចាំនូវការអនុវត្តកម្មវិធីប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំត្រីមាស និងរិះរកវិធានការទាន់ពេលវេលាក្នុងករណីចាំបាច់ ជាពិសេសត្រូវគោរព និងអនុវត្តតាមបទបញ្ជារបស់រាជរដ្ឋាភិបាលស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធលេខ០៤បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦។ ទន្ទឹមនឹងនេះ ដើម្បីឲ្យការអនុវត្តកម្មវិធីប្រមូលចំណូលប្រចាំត្រីមាសសម្រេចបានប្រកបដោយប្រសិទ្ធភាពខ្ពស់ អង្គភាពនីមួយៗត្រូវធ្វើការតាមដាន និងត្រួតពិនិត្យជាប្រចាំ (ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំត្រីមាស)លើលទ្ធផលសម្រេចបាន ដើម្បីរិះរកវិធានការទាន់ពេលវេលាក្នុងករណីចាំបាច់ ព្រមទាំងធ្វើរបាយការណ៍អនុវត្តចំណូលប្រចាំសប្តាហ៍ ប្រចាំខែ និងប្រចាំត្រីមាសស្តីពីការអនុវត្តចំណូលរបស់ខ្លួនសម្រាប់ដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ និងមានវិធានការតាមរយៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយលើកឡើងពីលទ្ធផលដែលសម្រេចបាន និងចំណុចខ្វះខាតដែលបានកត់សំគាល់ ព្រមទាំងលើកឡើងនូវសំណូមពរ និងអនុសាសន៍ដើម្បីកែលម្អ និងបង្កើនប្រសិទ្ធភាពប្រមូលចំណូល។

៩- លើសពីនេះទៅទៀត ដើម្បីធានាការប្រមូលចំណូលតាមគោលនយោបាយខាងលើនេះ ជាពិសេស ក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ចេញនូវបណ្តាវិធានការមួយចំនួនដូចខាងក្រោម៖

<u>ទីមួយ- ការពង្រឹងសមត្ថភាពរួមសម្រាប់ការគ្រប់គ្រង និងប្រមូលចំណូលៈ</u>

- គ្រប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តដែលមានប្រភពចំណូលត្រូវបង់ចូលថវិការដ្ឋតាមរយៈគណនីទោលរតនាគារជាតិ ឲ្យបានទាន់ពេលវេលាស្របតាមបទប្បញ្ញត្តិហិរញ្ញវត្ថុសាធារណៈជាធរមាន បើពុំនោះទេ រដ្ឋមន្ត្រីក្រសួង ស្ថាប័ន និងអ្នកទទួលខុសត្រូវក្នុងការបង់ចំណូលទាំងនោះត្រូវទទួលពិន័យឲ្យបង់ការប្រាក់៥ភាគរយក្នុងមួយខែ ទៅតាមបរិមាណសាច់ប្រាក់ និងរយៈពេលដែលរក្សាទុកថវិការដ្ឋនៅក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តរបស់ខ្លួន។

- បន្តជំរុញការអនុវត្តបង្កាន់ដៃជាតិ ដើម្បីកែលម្អ និងបង្កើនប្រសិទ្ធភាពក្នុងការចុះបញ្ជីការត្រួតពិនិត្យ និងការគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទ។

- បន្តជំរុញការរៀបចំយន្តការ និងការណែនាំឲ្យអនុវត្តយ៉ាងម៉ឺងម៉ាត់ និងប្រកបដោយប្រសិទ្ធភាពនូវរាល់គោលការណ៍ច្បាប់ បទបញ្ជា និងវិន័យលើការប្រមូលចំណូលថវិការដ្ឋគ្រប់ប្រភេទ ជាពិសេសចំណូលមិនមែនសារពើពន្ធ។

- បន្តជំរុញការសិក្សា ស្វែងរកជម្រើស និងយន្តការក្នុងការបង្កើនការប្រមូល ការពង្រីកមូលដ្ឋាន និងការគ្រប់គ្រងចំណូលប្រកបដោយប្រសិទ្ធភាព ពិសេស ចំណូលពីប្រភពធនធានធម្មជាតិ ដូចជាប្រេង រ៉ែ និង ឧស្ម័ន។ រាជរដ្ឋាភិបាលបន្តជំរុញការបង្កើនសមត្ថភាពរបស់ខ្លួន ក្នុងការគ្រប់គ្រង "ចំណាយរបស់ក្រុមហ៊ុនក្នុងការរុករក និងអភិវឌ្ឍន៍អាជីវកម្មប្រេង រ៉ែ និងឧស្ម័ន" ដើម្បីធានាថា ការ

គណនា និងការគ្រប់គ្រងចំណូលដែលបានមកពីប្រេង រ៉ែ និងឧស្ម័ន ត្រូវបានគណនា និងគ្រប់គ្រងឈរលើមូលដ្ឋានស្មោះត្រង់ច្បាស់លាស់ និងត្រឹមត្រូវ។

- បន្តធ្វើបច្ចុប្បន្នភាពគោលនយោបាយចំណូលរយៈពេលមធ្យម និងដាក់ឲ្យអនុវត្ត ដើម្បីបង្កើនសមត្ថភាព និងសុក្រឹតភាពនៃការព្យាករណ៍ចំណូល សំដៅធានានិរន្តរភាព និងស្ថិរភាពនៃហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងការធ្វើសមាហរណកម្មធនធានថវិកាសំដៅបម្រើឲ្យការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យមប្រកបដោយភាពជាក់ស្តែង និងសុក្រឹត។

- បន្តជំរុញការអនុវត្ត ព្រមទាំងបង្កើនសុក្រឹតភាព និងប្រសិទ្ធភាពនៃផែនការយុទ្ធសាស្ត្រថវិកាដែលជាឧបករណ៍ដ៏សំខាន់សម្រាប់ការធ្វើសមាហរណកម្មចំណូល និងចំណាយទាំងក្នុង និងក្រៅប្រទេស សម្រាប់រយៈពេលមធ្យម ទៅក្នុងដំណើរការនៃការកសាងថវិកាឯកភាពមួយ ដើម្បីបង្កើនភាពគ្រប់ជ្រុងជ្រោយ និងជាបណ្តើរៗ ធានាបានការផ្សាភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។

- បន្តជំរុញការកំណត់ឲ្យបានច្បាស់លាស់នូវបំណុលពន្ធ និងបំណុលនៃចំណូលមិនមែនសារពើពន្ធ ដើម្បីរៀបចំផែនការប្រមូល និងតឹងទារឲ្យមានប្រសិទ្ធភាព។

- បន្តជំរុញការបង្កើតក្របខ័ណ្ឌសម្រាប់កៀរគរ និងបែងចែកចំណូលទៅតាមគ្រប់លំដាប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្តល់ការណែនាំដល់ការកសាងវិធានការ សំដៅបង្កើនធនធាននៅតាមរាជធានី-ខេត្ត ក្រុង-ស្រុក និងឃុំ-សង្កាត់ ក្រោមកម្មវិធីវិសហមជ្ឈការសារពើពន្ធ។

- បន្តជំរុញពង្រឹងការងារសវនកម្មទាំងសវនកម្មផ្ទៃក្នុងរបស់ក្រសួង ស្ថាប័នទាំងការងារអធិការកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការពង្រឹងការគ្រប់គ្រងថវិកា ជាពិសេសលើការប្រមូលចំណូល។

- ជំរុញឲ្យអង្គភាពរងសវនកម្មខិតខំកែលម្អតាមអនុសាសន៍ដែលបានផ្តល់។

- អគ្គនាយកដ្ឋានពន្ធដារ និងនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ត្រូវរៀបចំក្របខ័ណ្ឌគតិយុត្តិ នីតិវិធីនិងយន្តការចាំបាច់ដើម្បីអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា១២, ១៣ និង១៤ ស្តីពីពន្ធប្រថាប់ត្រា និងការគ្រប់គ្រងបរធនបាលកិច្ចហិរញ្ញវត្ថុក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។

<u>ទីពីរ- ការកៀរគរចំណូលផ្នែកគយនិងរដ្ឋាករ:</u>

- បន្តជំរុញការរៀបចំតាមការចាំបាច់នូវលិខិតបទដ្ឋាននានា ដើម្បីជំរុញការអនុវត្តច្បាប់ស្តីពីគយ ពិសេសសម្រាប់បន្តកែលម្អបរិស្ថានធុរកិច្ច និងវិនិយោគ និងសម្រាប់រឹតបន្តឹងវិធានការបំបាត់អំពើរត់ពន្ធគយ។

- បន្តកែលម្អនីតិវិធីក្នុងការគ្រប់គ្រងអ្នកនាំទំនិញចេញ-ចូល ដោយតម្រូវឲ្យមានការរៀបចំជាក្រុមហ៊ុននាំចេញ-ចូល និងក្រុមហ៊ុនដើងសារច្បាស់លាស់ ដើម្បីធានានូវតម្លាភាព និងភាពងាយស្រួលក្នុងការត្រួតពិនិត្យ និងក្នុងការយកពន្ធ និងអាករផ្សេងៗ។

- បន្តរៀបចំកែលម្អ និងដាក់ឲ្យអនុវត្តនូវរចនាសម្ព័ន្ធចាត់តាំងថ្មីរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

- បន្តជំរុញការអនុវត្តវិធានការតឹងរឹងក្នុងការបង្កើនចំណូលពន្ធគយរួមមាន៖

▪ បន្តពង្រឹងការអនុវត្តបណ្តាវិធានការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងកងកម្លាំងប្រដាប់អាវុធ កងកម្លាំងនគរបាល អង្គភាពប្រឆាំងអំពើពុករលួយ និងអាជ្ញាធរដែនដី។ គណៈកម្មាធិការបង្ក្រាបអំពើរត់ពន្ធត្រូវបន្តពង្រឹងការអនុវត្តការងាររបស់ខ្លួនឲ្យកាន់

តែខ្លាំងក្លា និងប្រកបដោយប្រសិទ្ធភាពថែមទៀតក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ។ ក្នុងការអនុវត្តភារកិច្ចនេះ ត្រូវយកចិត្តទុកដាក់ជាពិសេស លើវិធានការកែលម្អផែនការសកម្មភាពបង្ក្រាបអំពើរត់ពន្ធ ដោយផ្តោតលើមុខទំនិញមួយចំនួន ដែលមានវេទយិតភាពដូចជា ប្រេងឥន្ធនៈ មធ្យោបាយដឹកជញ្ជូន បរិក្ខារ អេឡិចត្រូនិច និងការដាក់ចេញនូវនីតិវិធីត្រួតពិនិត្យថ្មី។

- បន្តពង្រឹងការសហការជាមួយអគ្គនាយកដ្ឋានពន្ធដារក្នុងការចែករំលែក និងផ្លាស់ប្តូរព័ត៌មានថ្មីៗទាន់ពេលវេលា រួមទាំងការប្រើប្រាស់មធ្យោបាយអេឡិចត្រូនិចស្តីពីសហគ្រាសធំៗ ដើម្បីពង្រឹងវិន័យ និងកាតព្វកិច្ចពន្ធដារ។ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានឹងបន្តផ្តល់ព័ត៌មានពីការនាំចូលទំនិញមកអគ្គនាយកដ្ឋានពន្ធដារឲ្យបានទៀងទាត់ និងរៀងរាល់ខែបន្ទាប់ពីក្រុមហ៊ុនបាននាំចូល។
- បន្តរិះរក និងដាក់ឲ្យអនុវត្តនូវវិធានការច្បាស់លាស់ និងទន់ភ្លន់ លើមុខទំនិញមួយចំនួន ដើម្បីរក្សាប្រភពចំណូល។
- បន្តជំរុញកែសម្រួលនីតិវិធីនៃការគ្រប់គ្រងផលិតផលគេលសិលានាំចូលឲ្យបានច្បាស់លាស់ងាយស្រួលក្នុងការកំណត់មុខសញ្ញាល្មើស និងការបង្ក្រាបកណ្តាលទី និងចុងទី រួមមានការគ្រប់គ្រងធុរជន ការគ្រប់គ្រងលិខិតដឹកជញ្ជូន និងការតម្រូវឲ្យចែកចាយតែតាមស្ថានីយដែលមានស្លាកសញ្ញាក្រុមហ៊ុននាំចូលស្របច្បាប់នូវផលិតផលទាំងនេះតែប៉ុណ្ណោះ។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារនឹងសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីចុះធ្វើការត្រួតពិនិត្យការលក់ប្រេងនៅតាមស្ថានីយលក់ប្រេងដែលមិនមានដាក់ស្លាកសញ្ញា។
- បន្តជំរុញការអនុវត្តនូវគោលនយោបាយជាតិពាក់ព័ន្ធនឹងការងារទប់ស្កាត់ និងបង្ក្រាបអំពើរត់ពន្ធឲ្យបានឆាប់ ជាពិសេស កំណត់ឲ្យបានច្បាស់លាស់នូវតួនាទី ភារកិច្ច ដែនសមត្ថកិច្ច និងការគ្រប់គ្រងមន្ត្រីរាជការគយដែលទទួលបន្ទុកការងារទប់ស្កាត់ និងបង្ក្រាបអំពើរត់ពន្ធគ្រប់ថ្នាក់។

- បន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការពង្រឹងស្ថាប័នគយនិងរដ្ឋាករមានជាអាទិ៍: បន្តការបណ្តុះបណ្តាល និងការបង្កើនសមត្ថភាពវិជ្ជាជីវៈ ការបំពាក់ឧបករណ៍ការងារ និងសីលធម៌របស់មន្ត្រីគយ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និងរដ្ឋបាលគយឲ្យបានរឹងមាំ។

- បន្តពិនិត្យស៊ីជម្រៅគោលនយោបាយពន្ធអាករគយ ឈានទៅកែសម្រួលអាករលើការនាំចេញ នាំចូលមួយចំនួន ជាពិសេស យានយន្ត កៅស៊ូកែច្នៃ និងទំនិញរសើបផ្សេងទៀត ដើម្បីរក្សាតុល្យភាពចំណូលដែលបាត់បង់ដោយការបញ្ចុះអត្រាពន្ធគយតាមស្មារតីនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានាក៏ដូចជាឈានទៅកាត់បន្ថយអំពើរត់ពន្ធតាមរយៈការកាត់បន្ថយគំលាតតម្លៃទំនិញរសើបលក់រាយតាមតំបន់ព្រំដែនជាមួយប្រទេសជិតខាង។

- បន្តចាត់វិធានការបន្ថែមទៀតដើម្បីជំរុញឲ្យម៉ូតូដែលបានធ្វើស្ថិតិរួចហើយ មកបង់ពន្ធនាំចូលឲ្យបានទាន់ពេលវេលា។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជានឹងធ្វើការសិក្សាអំពីការយកពន្ធលើការនាំចូលប្រេង ព្រោះការប្រើប្រាស់ប្រេងបច្ចុប្បន្នមិនមែនពាក់ព័ន្ធតែម្ចាស់រថយន្តឬម៉ូតូប៉ុណ្ណោះទេ ប៉ុន្តែវាប៉ះពាល់ដល់ប្រសិទ្ធភាពនៃសេដ្ឋកិច្ចទាំងមូល ជាពិសេស ការប្រើប្រាស់ប្រេងសម្រាប់ការស្រោចស្រពដំណាំស្រូវតែម្តង។

- បន្តពង្រឹង និងពង្រីកការអនុវត្តស្វ័យប្រវត្តិកម្មនីតិវិធីគយ ការអនុវត្តយន្តការសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយដល់អាជីវកម្មដ្ឋានធុរជន និងយន្តការគ្រប់គ្រងហានិភ័យ ដើម្បីកែលម្អប្រព័ន្ធការងារ បង្កើនប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ និងលើកកំពស់គុណភាពសេវាកម្ម ជូនដល់អតិថិជន។

- បន្តពង្រឹងការងារអភិបាលកិច្ចរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាឲ្យបំពេញការងារប្រកបដោយការទទួលខុសត្រូវ និងស្មារតីលះបង់ដោយឈរលើមូលដ្ឋានច្បាប់ និងបទប្បញ្ញត្តិជាធរមាន រាប់បញ្ចូលទាំងលទ្ធភាពដាក់ទណ្ឌកម្មចំពោះមន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចដែលឃុបឃិតធ្វេសប្រហែស ឬគ្មានសមត្ថភាពបណ្តោតបណ្តោយឲ្យមានការរត់ពន្ធ។

<u>ទីបី-ការកៀរគរចំណូលពន្ធដារៈ</u>

- បន្តជំរុញការអនុវត្តជាប្រព័ន្ធនូវកម្មវិធីកែលម្អគោលនយោបាយ និងពង្រឹងរដ្ឋបាលសារពើពន្ធ ក្នុងក្របខ័ណ្ឌកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២។

- បន្តពិនិត្យការអនុវត្ត ជំរុញ និងកែលម្អការប្រមូលពន្ធលើអចលនវត្ថុ ដើម្បីបង្កើនប្រសិទ្ធភាពសេវា និងការប្រមូលពន្ធលើអចលនវត្ថុ។

- បន្តពង្រឹង និងកែលម្អរដ្ឋបាលពន្ធដារ ពង្រឹងការងារសវនកម្មពន្ធ ពិនិត្យលទ្ធភាពពង្រីកមូលដ្ឋានយកពន្ធ បង្កើនប្រសិទ្ធភាពនៃការប្រមូលពន្ធ និងការធ្វើវិចារណកម្មប្រព័ន្ធលើកទឹកចិត្ត។

- បន្តពង្រឹងការអនុវត្តកម្មវិធីកែលម្អរចនាសម្ព័ន្ធ ជាពិសេស ការពង្រឹងការអនុវត្តតួនាទី ភារកិច្ច និងប្រតិបត្តិការរបស់អគ្គនាយកដ្ឋានពន្ធដារ ស្របតាមប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារ។

- បន្តបញ្ចប់ការកសាង និងចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មាន ជាពិសេសខាងផ្នែកប្រមូលពន្ធ ដូចជាការផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម និងការត្រួតពិនិត្យប្រទាក់ក្រឡាគ្នា។

- បន្តពង្រឹងការអនុវត្តឲ្យបានគ្រប់ជ្រុងជ្រោយ និងឲ្យបានម៉ឺងម៉ាត់នូវរាល់បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មទាំងឡាយនៃច្បាប់នេះ។

- បន្តអនុវត្តគោលនយោបាយពង្រីកមូលដ្ឋានយកពន្ធតាមរយៈការពង្រីក និងពង្រឹងការអនុវត្តរបបពិតនៅតាមបណ្តារាជធានី ខេត្ត និងបន្តពង្រឹងការគ្រប់គ្រង និងការប្រមូលពន្ធលើអ្នកជាប់ពន្ធតាមរបបម៉ៅការ។

- បន្តបណ្តុះបណ្តាល និងបង្កើនសមត្ថភាពវិជ្ជាជីវៈ និងសីលធម៌របស់មន្ត្រីពន្ធដារ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និងរដ្ឋបាលពន្ធដារឲ្យបានរឹងមាំ ក្នុងគោលដៅគ្រប់គ្រងឲ្យបានល្អនូវអ្នកបង់ពន្ធធំ និងមធ្យម។

- បន្តជំរឿនអ្នកជាប់ពន្ធនៅតាមរាជធានី ខេត្ត ក្នុងនោះមានជំរឿនសហគ្រាស យានយន្ត អចលនទ្រព្យ និងដីធ្លីមិនបានប្រើប្រាស់ សំដៅពង្រីកមូលដ្ឋានជាប់ពន្ធ ប្រមូលពន្ធឲ្យអស់លទ្ធភាព។

- បន្តជំរុញការអនុវត្តច្បាប់ជាធរមាន ដោយរៀបចំលិខិតបទដ្ឋាន ដើម្បីដាក់ឲ្យអនុវត្តបទប្បញ្ញត្តិនៃច្បាប់ស្តីពីពន្ធលើអចលនទ្រព្យ បទប្បញ្ញត្តិស្តីពីពន្ធលើប្រាក់ចំណេញមូលធន និងបទប្បញ្ញត្តិស្តីពីពន្ធលើកតិសន្យា។

- បន្តជំរុញការរៀបចំកែលម្អគោលនយោបាយសារពើពន្ធ ក្នុងនោះមានការរៀបចំគំរូសន្ធិសញ្ញាស្ដីពីការចៀសវាងការយកពន្ធត្រួតគ្នា ច្បាប់ស្ដីពីពន្ធលើប្រតិបត្តិការប្រេងកាតនិងឧស្ម័ន ច្បាប់ស្ដីពីពន្ធលើប្រតិបត្តិការធនធានរ៉ែ ជាអាទិ៍មានរ៉ែមាស និងលោហធាតុ និងត្បូងថ្មមានតម្លៃដទៃទៀត និងថ្ម ខ្សាច់ ដី។

- បន្តអប់រំពន្យល់ណែនាំដោយផ្ទាល់ និងតាមរយៈការផ្សព្វផ្សាយសេចក្ដីជូនដំណឹង និងសៀវភៅណែនាំនានា ដើម្បីឲ្យអ្នកជាប់ពន្ធបានយល់ច្បាស់លាស់ពីកាតព្វកិច្ចរបស់ខ្លួន គោរពប្រតិបត្តិច្បាប់ពន្ធដារល្អប្រសើរដោយស្ម័គ្រចិត្ត និងបង់ប្រាក់ពន្ធបានត្រឹមត្រូវ។

- បន្តអនុវត្តវិធានការបង្ខំ ក្នុងនោះមានការធ្វើសវនកម្ម និងការទារបំណុលពន្ធដែលត្រូវបន្តវិធានការតឹងទារបំណុលពន្ធឲ្យបានខ្លាំងក្លាចំពោះអ្នកជាប់ពន្ធដែលជំពាក់បំណុលពន្ធ។ វិធានការតឹងទារដែលអគ្គនាយកដ្ឋានបានកំពុងនឹងបន្តអនុវត្តរួមមាន៖

- សហការជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ និងធនាគារឲ្យឃាត់ទុកគណនីអ្នកជំពាក់បំណុលពន្ធ
- ស្នើសុំកិច្ចសហការពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបញ្ឈប់ប្រតិបត្តិនាំចេញ-នាំចូលចំពោះអ្នកជំពាក់បំណុលពន្ធដែលមានសកម្មភាពនាំចេញ-នាំចូល
- ស្នើសុំឲ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាធ្វើការព្យួរការពិនិត្យឯកសារវិនិយោគរបស់សហគ្រាសដែលជំពាក់បំណុលពន្ធ
- ព្យួរទុកការផ្ទេរកម្មសិទ្ធិកាន់កាប់អចលនទ្រព្យ
- ដំណើរការកាត់ក្ដីបំណុលពន្ធទៅតុលាការចំពោះសហគ្រាសរឹងរូសមួយចំនួន។ល។

- បន្តធ្វើការសិក្សាអំពីវិចារណកម្មបន្តនិងលទ្ធភាពវិសោធនកម្មលើច្បាប់ស្ដីពីសារពើពន្ធ (ពន្ធដារ) និងបណ្ដាច្បាប់ពាក់ព័ន្ធក្នុងគោលដៅបង្កើនចំណូលថវិកាជាតិ ដែលក្នុងនោះនឹងពិចារណាធ្វើវិសោធនកម្មមាត្រា២នៃអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីអាករលើតម្លៃបន្ថែម ដើម្បីបញ្ចុះផលរបរ និងបង្កើនចំនួនអ្នកជាប់ពន្ធតាមរបបឆ្លើយប្រកាសឲ្យបានច្រើន។

- បន្តជំរុញការប្រមូលពន្ធលើការលក់ទំនិញហូបចុក និងសេវាកម្មផ្សេងៗ ដែលមិនមែនជាសកម្មភាព ឬជាមុខរបររបស់ក្រុមហ៊ុនកាស៊ីណូ។

- បន្តពង្រឹងលិខិតបទដ្ឋានស្ដីពីពន្ធក្នុងវិស័យប្រេងនិងឧស្ម័ន ដើម្បីធានាឲ្យបាននូវការប្រមូលចំណូល ប្រកបដោយប្រសិទ្ធភាពពីវិស័យនេះ ជាពិសេស ការបន្តពិនិត្យពិចារណាលើការធ្វើវិសោធនកម្ម លើច្បាប់ស្ដីពីសារពើពន្ធ ដើម្បីរៀបចំបញ្ចូលពន្ធលើប្រេងនិងឧស្ម័ន។

- បន្តធ្វើការសិក្សាអំពីវិចារណកម្មបន្ត និងលទ្ធភាពវិសោធនកម្មបន្តលើច្បាប់ស្ដីពីសារពើពន្ធនិងបណ្ដាច្បាប់ពាក់ព័ន្ធក្នុងគោលដៅបង្កើនចំណូលថវិកាជាតិ។

- បន្តពង្រឹងការងារអភិបាលកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ។

ទីបួន-ការពង្រឹងការគ្រប់គ្រង និងការកៀរគរចំណូលមិនមែនសារពើពន្ធ៖

- បន្តជំរុញការប្រើប្រាស់បង្កាន់ដៃបង់ប្រាក់សម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទនៅតាមគ្រប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តក្នុងគោលដៅបង្កើនការគ្រប់គ្រង

និងការប្រមូលចំណូលតាមរយៈការសហការជាមួយក្រសួង ស្ថាប័ន អង្គភាព មន្ទីរ ក្រុមហ៊ុនពាក់ព័ន្ធ ដើម្បីពង្រឹងយន្តការត្រួតពិនិត្យចំណូលមិនមែនសារពើពន្ធ និងចាត់វិធានការជំរុញបង់បំណុលរ៉ាំរ៉ៃ។

- បន្តជំរុញការអនុវត្តឲ្យមានប្រសិទ្ធភាពនូវច្បាប់ និងលិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ពិសេសបទបញ្ជារបស់នាយករដ្ឋមន្ត្រីលេខ០២បប ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

- អនុវត្តឲ្យបានម៉ឺងម៉ាត់នូវប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈ ដែលបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រី/ប្រធាននៃក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយមានការចូលរួមរៀបចំដោយប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ដើម្បីធានាបាននូវការប្រមូលចំណូលឲ្យមានប្រសិទ្ធភាព ដោយឈរលើស្មារតីទទួលខុសត្រូវ និងប្រុងប្រយ័ត្នខ្ពស់។

- បន្តពង្រឹងការគ្រប់គ្រងសហគ្រាសសាធារណៈ ពិសេស ការបង់ពន្ធ និងការបង់ពន្ធលើប្រាក់ចំណេញជូនរដ្ឋ។

- បន្តជំរុញការអនុវត្តឲ្យមានប្រសិទ្ធភាពនូវច្បាប់ និងលិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធ ពិសេសបទបញ្ជារបស់នាយករដ្ឋមន្ត្រីលេខ០៤បប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

- បន្តជំរុញការពង្រឹងការប្រមូលចំណូលពីកិច្ចសន្យាសម្បទានគ្រប់ប្រភេទ ដើម្បីធានាឲ្យមានការបង់ចំណូលទាំងនេះចូលថវិការដ្ឋឲ្យបានទៀងទាត់ ទាន់ពេលវេលា និងដោយគ្មានការកាត់ទុកសម្រាប់ចំណាយដោយប្រការណាមួយឡើយ។

- បន្តជំរុញដើម្បីបញ្ចប់ការងារធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ហើយចាប់ផ្តើមធ្វើបញ្ជីសារពើភ័ណ្ឌដីរបស់រដ្ឋជាបណ្តើរៗ ដើម្បីពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការប្រមូលចំណូល។

- បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីសម្បទាន និងពង្រឹងកិច្ចដំណើរការផ្តល់ និងគ្រប់គ្រងកិច្ចសន្យាសម្បទានគ្រប់ប្រភេទទាំងអស់ ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពីកិច្ចសន្យាសម្បទានគ្រប់ប្រភេទចូលថវិកាជាតិ។

- បន្តពង្រឹងការគ្រប់គ្រងចំណូលពីផលទុនប្រៃសណីយ៍ និងទូរគមនាគមន៍ តាមរយៈការពង្រឹងយន្តការតឹងទារចំណូល ដោយតម្រូវឲ្យក្រុមហ៊ុនទូរស័ព្ទទាំងអស់បង់ចំណូលដោយត្រង់ទៅក្នុងគណនីរបស់រាជរដ្ឋាភិបាលនៅធនាគារជាតិ ហើយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ការបង់ចំណូលនេះ។

- បន្តជំរុញការអនុវត្តការផ្តល់វិញ្ញាបនបត្រវិជ្ជាជីវៈ និងការអនុញ្ញាតលើការប្រកបសេវាកម្មវាយតម្លៃ និងការជួញដូរអចលនវត្ថុ ដើម្បីពង្រឹងការគ្រប់គ្រងទីផ្សារ និងការប្រមូលពន្ធ។

- បន្តចុះសិក្សា និងស្រាវជ្រាវរាល់បំណុលទាំងអស់ ដើម្បីរៀបចំគោលការណ៍ និងនីតិវិធីតឹងទារ ឬដោះស្រាយតាមផ្លូវច្បាប់ចំពោះបំណុលរ៉ាំរ៉ៃ។ ពិសេសកំណត់ឲ្យបានច្បាស់នូវបំណុលពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ ហើយបន្តជំរុញការអនុវត្តនូវផែនការសកម្មភាព និងបណ្តាវិធានការដើម្បីតឹងទារបំណុលទាំងអស់នេះតាមគ្រប់មុខសញ្ញាទាំងអស់។ ក្នុងនេះត្រូវផ្តោតការយកចិត្តទុកដាក់

ជាពិសេសទៅលើការគ្រប់គ្រងចំណូលពីអាកាសចរស៊ីវិល ចំណូលពីវិស័យទេសចរណ៍ ចំណូលផ្សាយពាណិជ្ជកម្ម ចំណូលទិដ្ឋាការ និងចំណូលពីការជួលរោងចក្រសហគ្រាស និងទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀត។

**ខ- ការអនុវត្តចំណាយថវិកា**

**១០**-ដើម្បីធានាដល់ការអនុវត្តថវិកាឆ្នាំ២០១៣ប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងសម្រេចបានតាមគោលដៅនៃ**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ជាពិសេសដើម្បីបម្រើឲ្យការអនុវត្ត**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២**របស់រាជរដ្ឋាភិបាល ការគ្រប់គ្រងចំណាយត្រូវបន្តពង្រឹងបន្ថែមទៀត និងត្រូវពង្រឹងការគោរពច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិថ្នាក់ក្រោមជាតិ ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងច្បាប់ស្តីពីហិរញ្ញវត្ថុដទៃទៀត ជាពិសេស ការគោរពឲ្យបានដាច់ខាតនូវវិន័យថវិកាទាំង១១ខ។ ទន្ទឹមនឹងនេះ ត្រូវបន្តពង្រឹងការអនុវត្តអភិបាលកិច្ចល្អក្នុងការអនុវត្តថវិកា និងការគ្រប់គ្រងថវិកា ជាពិសេស ការអនុវត្តឲ្យបានម៉ឺងម៉ាត់នូវរាល់ការកែលម្អលើការអនុវត្តថវិកាក្នុងក្របខណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**ខ.១-<u>ការរៀបចំ និងការអនុវត្តកម្មវិធីចំណូល-ចំណាយ</u>**

**១១**- ដើម្បីឲ្យការអនុវត្តថវិកាប្រកបដោយភាពជឿទុកចិត្តបាន និងប្រព្រឹត្តទៅដោយរលូន ជាពិសេស ដើម្បីធានាការឆ្លើយតបទៅនឹងតម្រូវការចំណាយជាក់ស្តែងឲ្យទាន់ពេលវេលាប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ គ្រប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ត្រូវរៀបចំគម្រោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសសម្រាប់រយៈពេលពេញ១ឆ្នាំ ដែលមានបែងចែកលម្អិតទៅតាមខែ និងទៅតាមគំរូដែលរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយឈរលើមូលដ្ឋាននៃតម្រូវការចំណាយជាក់ស្តែង (តាមប្រតិទិននៃផែនការសកម្មភាពការងារ និងផែនការលទ្ធកម្ម) និងក្នុងក្របខ័ណ្ឌនៃឥណទានដែលត្រូវបានកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។ ក្រសួង ស្ថាប័ន ត្រូវផ្ញើកម្មវិធីចំណូល-ចំណាយដែលបានរៀបចំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(នាយកដ្ឋានថវិកា និងនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ) ដោយឡែកមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ ត្រូវផ្ញើកម្មវិធីចំណូល-ចំណាយដែលបានរៀបចំទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមួយច្បាប់ដើម្បីបូកសរុបរួចផ្ញើមកនាយកដ្ឋានថវិកា និងនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និងផ្ញើទៅក្រសួង ស្ថាប័នដែលជាខ្សែបណ្តោយរបស់ខ្លួនមួយច្បាប់សម្រាប់ការគ្រប់គ្រង និងតាមដានការអនុវត្ត។ ក្រោយពីទទួលបានកម្មវិធីចំណូល-ចំណាយដែលស្នើឡើងដោយក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវពិនិត្យ និងវាយតម្លៃដោយផ្អែកទៅលើអាទិភាពនៃតម្រូវការ និងលទ្ធភាពចំណូលដែលអាចប្រមូលបានដើម្បីដាក់ចេញជាកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសទៅតាមមាតិកាថវិកាសម្រាប់ការអនុវត្ត។

**១២**- ដើម្បីបន្តធានា និងបង្កើនភាពជឿទុកចិត្តបានលើថវិកា ជាពិសេស ដើម្បីបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ឲ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត ការរៀបចំកម្មវិធីចំណូល-ចំណាយប្រចាំត្រី

មាសឲ្យកាន់តែបានត្រឹមត្រូវនិងសុក្រឹតព្រមទាំងការអនុវត្តឲ្យបានម៉ឺងម៉ាត់តាមកម្មវិធីចំណូល-ចំណាយនេះគឺជាប្រការចាំបាច់បំផុត។ ដូច្នេះ គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញរាជធានី ខេត្តទាំងអស់ និងអគ្គនាយកដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវអនុវត្តឲ្យបានម៉ឺងម៉ាត់នូវនីតិវិធីដូចខាងក្រោម៖

- នៅរៀងរាល់ថ្ងៃទី២០នៃខែនាចុងត្រីមាសនីមួយៗ អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ក្រសួង ស្ថាប័ន និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្ញើមកនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ នូវរបាយការណ៍ប៉ាន់ស្មានអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសកំពុងអនុវត្តដោយឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែងប្រចាំខែទី១ និងខែទី២ និងការប៉ាន់ស្មានអនុវត្តខែទី៣ ជាមួយនឹងការស្នើឡើងនូវការកែសម្រួលគម្រោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសបន្ទាប់ប្រសិនបើចាំបាច់។

- ដោយឡែកមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ត្រូវផ្ញើរបាយការណ៍ប៉ាន់ស្មានអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសកំពុងអនុវត្តដោយឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែងប្រចាំខែទី១ និងខែទី២ និងការប៉ាន់ស្មានអនុវត្តខែទី៣ ជាមួយនឹងការស្នើឡើងនូវការកែសម្រួលគម្រោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសបន្ទាប់ប្រសិនបើចាំបាច់ទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឲ្យបានមុនថ្ងៃទី២០នៃខែនាចុងត្រីមាសនីមួយៗដើម្បីទុកពេលវេលាឲ្យមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបូកសរុបរួចផ្ញើមកនាយកដ្ឋានថវិកានិងអង្គភាពគ្រប់គ្រងសាច់ប្រាក់ឲ្យបានទាន់ពេលវេលា។

- នៅរៀងរាល់ថ្ងៃទី២៥នៃខែនាចុងត្រីមាសនីមួយៗនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវរៀបចំប្រជុំពិភាក្សាជាមួយអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានរតនាគារជាតិ និងនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីរៀបចំកម្មវិធីចំណូល-ចំណាយថវិកាថ្នាក់ជាតិសម្រាប់ត្រីមាសបន្ទាប់។ ផ្អែកលើមូលដ្ឋាននៃកម្មវិធីចំណូល-ចំណាយនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(នាយកដ្ឋានថវិកា) ត្រូវរៀបចំប្រកាសប្រគល់កម្មវិធីចំណូល-ចំណាយសម្រាប់ត្រីមាសបន្ទាប់ទៅតាមមាតិកាថវិកាក្នុងកម្រិតឥណទានអតិបរមាជូនដល់ក្រសួង ស្ថាប័ននីមួយៗ និងមន្ទីរជំនាញរាជធានី ខេត្តនីមួយៗ ដោយចម្លងជូននាយកដ្ឋានហិរញ្ញកិច្ច អគ្គនាយកដ្ឋានរតនាគារជាតិ និងគណៈអភិបាលរាជធានី ខេត្ត។

- អាណាប័កដើមខ្សែ ឬអាណាប័កតាមការប្រទានសិទ្ធិ ត្រូវចេញអាណត្តិបើកប្រាក់នៅក្នុងវង្វង់នៃកម្មវិធីចំណាយប្រចាំត្រីមាសរបស់ខ្លួន ហើយនាយកដ្ឋានហិរញ្ញកិច្ច មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រតនាគាររាជធានី ខេត្ត និងអគ្គនាយកដ្ឋានរតនាគារជាតិត្រូវចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ និងត្រូវបើកជាសាច់ប្រាក់តែនៅក្នុងកម្រិតនៃកម្មវិធីចំណូល-ចំណាយ និងសាច់ប្រាក់ប្រចាំត្រីមាសនេះតែប៉ុណ្ណោះ។

- អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានរតនាគារជាតិ នាយកដ្ឋានហិរញ្ញកិច្ច នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន

ក្រសួង ស្ថាប័ន និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវផ្ញើរបាយការណ៍អនុវត្តចំណូល-ចំណាយប្រចាំខែមកនាយកដ្ឋានថវិកា និងនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឲ្យបានមុនថ្ងៃទី១៥នៃខែបន្ទាប់។

- អគ្គនាយកដ្ឋានរតនាគារជាតិត្រូវបញ្ជូនមកនាយកដ្ឋានថវិកានូវរបាយការណ៍ចំណូល-ចំណាយថវិកាប្រចាំខែ របាយការណ៍បុរេប្រទាន និងតារាងតុល្យភាពនៃគណនីប្រចាំខែ ដើម្បីតាមដានបូកសរុបចំណូល-ចំណាយថវិកាប្រចាំខែ ប្រចាំត្រីមាស ព្រមទាំងធ្វើការសន្និដ្ឋាន វាយតម្លៃនូវសភាពការណ៍អនុវត្តធៀបនឹងខែមុន ត្រីមាសមុននៃឆ្នាំនេះ និងប្រៀបធៀបទៅនឹងខែត្រីមាសដូចគ្នានៃឆ្នាំមុន។

- រតនាគារនៅថ្នាក់មូលដ្ឋានត្រូវបញ្ជូនមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនូវរបាយការណ៍ចំណូល-ចំណាយថវិកាប្រចាំខែ ដើម្បីតាមដានបូកសរុបចំណូល-ចំណាយថវិកាប្រចាំខែ ប្រចាំត្រីមាស និងដើម្បីឲ្យមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើរបាយការណ៍ផ្ញើមកនាយកដ្ឋានថវិកា និងនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ខ.២- <u>ការផ្តល់ធានាចំណាយ</u>**

- ទាំងថវិកាកម្មវិធី និងមិនមែនកម្មវិធី ការសុំ និងការផ្តល់ធានាចំណាយត្រូវអនុវត្តទៅតាមប្រភេទចំណាយធំៗបី ដូចខាងក្រោម៖
  - ***ចំណាយបន្ទុកបុគ្គលិក(ជំពូក៦៤)***ពុំតម្រូវឲ្យមានការសុំធានាចំណាយដាច់ដោយឡែកទេ គឺត្រូវបោះផ្សាយអាណត្តិបើកប្រាក់តែម្តង ដោយឈរលើមូលដ្ឋានឥណទានដែលមានទិដ្ឋាការបញ្ជាក់ពីចំនួនក្របខ័ណ្ឌ និងកាំប្រាក់ពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល។
  - ***ចំណាយដែលមិនតម្រូវឲ្យអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ និងចំណាយដែលមានរបបកំណត់ច្បាស់លាស់***ពុំតម្រូវឲ្យមានការសុំធានាចំណាយដោយឡែកទេ។ ចំណាយប្រភេទនេះមានដូចជា ការចំណាយតាមរយៈរដ្ឋទេយ្យបុរេប្រទាន និងចំណាយឧបត្ថម្ភផ្សេងៗដែលមានគោលការណ៍កំណត់រួចហើយ និងចំណាយលើអគ្គិសនី ទឹក ទូរស័ព្ទ។

- ***ចំណាយដែលតម្រូវឲ្យអនុវត្តកិច្ចលទ្ធកម្មសាធារណៈ***តម្រូវឲ្យមានការសុំធានាចំណាយស្របទៅតាមផែនការលទ្ធកម្ម។ ចំពោះចំណាយនេះ បើមិនមានកត់ត្រាក្នុងផែនការលទ្ធកម្មទេ មិនអនុញ្ញាតឲ្យសុំ ឬផ្តល់ការធានាចំណាយឡើយ។

- ចំពោះប្រភេទចំណាយដែលមិនតម្រូវឲ្យមានការសុំធានាចំណាយដោយឡែក អាណាប័កត្រូវធ្វើសាលាកប័ត្រ និងអាណត្តិសុំទូទាត់តែម្តង ដោយមានភ្ជាប់មកជាមួយនូវឯកសារ និងលិខិតយុត្តិការគ្រប់គ្រាន់ស្របទៅតាមនីតិវិធីទូទាត់ ។

- មិនអនុញ្ញាតឲ្យមានការផ្តល់ធានាចំណាយ និងការផ្តល់ទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេ ប្រសិនបើគ្មានការស្នើសុំជាលាយល័ក្ខណ៍អក្សរពីអាណាប័កដើមខ្សែ ឬអាណាប័កផ្ទេរសិទ្ធិ ទោះបីចំណាយនោះមានកត់ត្រាទុកនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុក៏ដោយ។

• ត្រូវសុំ និងផ្តល់ជានាចំណាយតែក្នុងកម្រិតឥណទានថវិកាដែលបានអនុម័ត និងដែលមាននៅសល់ទំនេរក្រោយពីដកស្តុកលើរាល់ការធានាចំណាយ និងការចំណាយជាក់ស្តែងរួមទាំងថវិកាបុរេប្រទានមិនទាន់ទូទាត់ផង ពិសេសបុរេប្រទានឆ្នាំ២០១២។

• មិនត្រូវសុំនិងផ្តល់ជានាចំណាយឲ្យលើសពីឥណទានថវិកាដែលបានអនុម័តមានលក្ខណៈកម្រិតកំណត់។

• មិនត្រូវសុំនិងផ្តល់ជានាចំណាយទៅលើការអនុវត្តនូវសកម្មភាពដែលនាំឲ្យមានការជ្រើសរើសមន្ត្រីថ្មី ឬមន្ត្រីជាប់កិច្ចសន្យានៅក្នុងឆ្នាំដែលកំពុងអនុវត្ត ដោយគ្មានការគ្រោងទុកក្នុងថវិកា ឬគ្មានសេចក្តីសម្រេចពីរាជរដ្ឋាភិបាល។

• មិនត្រូវលើកសំណើចំណាយបន្ថែម ប្រសិនបើគ្មានការសន្សំសំចៃពីខ្ទង់ចំណាយដទៃមកជានា។

• ក្នុងការសុំនិងផ្តល់ជានាចំណាយមិនត្រូវកាត់បន្ថយសកម្មភាពការងារ អនុកម្មវិធី ឬកម្មវិធីដែលបានអនុម័តរួចហើយនោះទេ លើកលែងតែមានការស្នើសុំពីសាមីក្រសួង ស្ថាប័ន ដោយមានបញ្ជាក់ពីហេតុផល និងផលប៉ះពាល់ច្បាស់លាស់ ហើយធានាថាមិនធ្វើឲ្យប៉ះពាល់ដល់ការសម្រេចគោលដៅសូចនាករនៃគោលនយោបាយរបស់ក្រសួង ស្ថាប័នដែលបានកំណត់ ឬគោលនយោបាយរបស់វិស័យ និងគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល។

**ខ.៣- <u>ការធ្វើលទ្ធកម្មសាធារណៈ</u>**

• គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពស្វយ័តភាពហិរញ្ញវត្ថុដទៃទៀត ត្រូវគោរពឲ្យបានម៉ឺងម៉ាត់នូវបទប្បញ្ញត្តិវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មសាធារណៈដូចមានចែងក្នុងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងឯកសារគតិយុត្តិ ព្រមទាំងលិខិតបទដ្ឋានពាក់ព័ន្ធលទ្ធកម្មសាធារណៈជាធរមាន ដូចជាអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ សៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាននិងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ សារាចរណែនាំលេខ០០៦ សហវ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពីការរៀបចំផែនការលទ្ធកម្មឆ្នាំ២០០៨និងឆ្នាំបន្តបន្ទាប់ និងបទប្បញ្ញត្តិផ្សេងៗទៀតស្តីពីលទ្ធកម្មសាធារណៈ។

• ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពស្វយ័តភាពហិរញ្ញវត្ថុដទៃទៀត ត្រូវប្រញាប់រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ២០១៣ ផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(តាមរយៈនាយកដ្ឋានលទ្ធកម្មសាធារណៈ) ដើម្បីពិនិត្យនិងអនុម័ត។

• សម្រាប់ការអនុវត្តថវិកាចាប់ពីឆ្នាំ២០១៤តទៅ ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពស្វយ័តភាពហិរញ្ញវត្ថុដទៃទៀតត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ ផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(តាមរយៈនាយកដ្ឋានលទ្ធកម្មសាធារណៈ) ដើម្បីពិនិត្យនិងអនុម័តឲ្យបានមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកាជាកំហិតស្របតាមខ្លឹមសារមាត្រា៣៥ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។

• ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ ត្រូវធ្វើឡើងដោយចងជា"ឡូត៍លទ្ធកម្ម" ឬ"កញ្ចប់លទ្ធកម្ម" ចំពោះមុខសញ្ញាលទ្ធកម្មដែលមានលក្ខណៈបច្ចេកទេសដូចគ្នា ឬប្រហាក់ប្រហែលគ្នា ស្របតាមតម្រូវការជាក់ស្តែង និងត្រូវមានសង្គតិភាពជាមួយកញ្ចប់ថវិកាប្រចាំឆ្នាំ។

• ក្នុងករណីចាំបាច់ អនុញ្ញាតឲ្យធ្វើផែនការលទ្ធកម្មកែតម្រូវ។ រាល់ការកែតម្រូវផែនការលទ្ធកម្មដោយសារមិនមានពេលគ្រប់គ្រាន់សម្រាប់អនុវត្តកិច្ចលទ្ធកម្ម ឬដើម្បីតម្រូវតាមកិច្ចលទ្ធកម្មដែលបានអនុវត្តរួច ត្រូវហាមឃាត់។

• ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈត្រូវធ្វើឡើងឲ្យស្របតាមវិធីសាស្ត្រនិងប្រតិទិនដែលបានកំណត់នៅក្នុងផែនការលទ្ធកម្ម។ **ឧទាហរណ៍**: ជាគោលការណ៍ ត្រូវអនុវត្តឱ្យបានដាច់ខាតចំពោះការផ្សព្វផ្សាយសេចក្តីជូនដំណឹងការដេញថ្លៃក្នុងរយៈពេលយ៉ាងតិច៦០ថ្ងៃ សម្រាប់ការដេញថ្លៃប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ និងយ៉ាងតិច៣០ថ្ងៃ សម្រាប់ការដេញថ្លៃប្រកួតប្រជែងក្នុងស្រុក។

• ហាមបំបែកគម្រោងជាគម្រោងតូចៗក្នុងគោលបំណងបំពានវិធីសាស្ត្រលទ្ធកម្ម ឬដើម្បីតម្រូវតាមសិទ្ធិសម្រេចរបស់ខ្លួន។

• តម្លៃកិច្ចសន្យាលទ្ធកម្ម មិនអនុញ្ញាតឲ្យលើសឥណទានថវិកាដែលបានផ្តល់ការធានាចំណាយឡើយ។ ករណីលើសពីឥណទានដែលបានផ្តល់ពេលធានាចំណាយ ត្រូវមានការសម្របសម្រួលរវាងអង្គភាពដែលផ្តល់ធានាចំណាយនិងនាយកដ្ឋានលទ្ធកម្មសាធារណៈ ឬអង្គភាពលទ្ធកម្ម (ករណីក្រោមសិទ្ធិសម្រេច)។

• មិនអនុញ្ញាតឲ្យធ្វើការប្រគល់ទទួលទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សា ដោយគ្មានកិច្ចសន្យាលទ្ធកម្មឡើយ ព្រោះកិច្ចសន្យាជាមូលដ្ឋានសំខាន់និងចាំបាច់បំផុតសម្រាប់ធ្វើការទូទាត់ ព្រមទាំងធ្វើការផ្ទៀងផ្ទាត់លក្ខណៈបច្ចេកទេស គុណភាព តម្លៃ រយៈពេលផ្គត់ផ្គង់ សាងសង់ ឬផ្តល់សេវាដែលភាគីទាំងពីរព្រមព្រៀងគ្នា។

• ក្នុងករណីចាំបាច់ដែលតម្រូវឲ្យមានការផ្លាស់ប្តូរលក្ខណៈបច្ចេកទេសទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សាដែលកំណត់ក្នុងកិច្ចសន្យា ត្រូវតែមានការឯកភាពជាលាយលក្ខណ៍អក្សររបស់ភាគីទាំងពីរ និងមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

• ក្នុងករណីការងារទទួលអនុវត្តដោយអង្គភាពរដ្ឋ ការទូទាត់ត្រូវរក្សាទឹកប្រាក់ចំនួន១០% នៃតម្លៃកិច្ចសន្យាសរុប ដើម្បីទុកជាការធានាគុណភាពជំនួសប្រាក់កក់ធានាការអនុវត្តកិច្ចសន្យារហូតដល់ផុតរយៈពេលធានាគុណភាពទើបធ្វើការទូទាត់ជូនបង្គ្រប់បញ្ចប់ បន្ទាប់ពីមានកំណត់ហេតុប្រគល់ទទួលបញ្ជាក់ថាបានអនុវត្តត្រឹមត្រូវតាមកិច្ចសន្យា។

• គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពស្វយ័តភាពហិរញ្ញវត្ថុដទៃទៀត ត្រូវធ្វើរបាយការណ៍អនុវត្តលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ(តាមគម្រូដែលបានកំណត់) មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(នាយកដ្ឋានលទ្ធកម្មសាធារណៈ)ឲ្យបានទៀងទាត់។

• រាល់ការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ឯកសារគតិយុត្តិនិងលិខិតបទដ្ឋានពាក់ព័ន្ធជាធរមាន ឬការពាក់ព័ន្ធនឹងអំពើពុករលួយ អំពើបន្លំ អំពើឃុបឃិត ឬអំពើ

បង្កិតបង្គំនៅក្នុងដំណើរការលទ្ធកម្មសាធារណៈ ត្រូវទទួលទោសទណ្ឌដូចមានចែងក្នុងមាត្រា៦៥ដល់មាត្រា៧៣ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។ មាត្រា៧៣នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈចែងថា "បទល្មើសពុករលួយដែលមានចែងក្នុងច្បាប់នេះ និងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ក៏ស្ថិតនៅក្រោមសមត្ថកិច្ចរបស់អង្គភាពប្រឆាំងអំពើពុករលួយ ដែលជាអង្គភាពតែមួយគត់មានសមត្ថកិច្ចស៊ើបអង្កេត និងកសាងសំណុំរឿងពុករលួយទៅតុលាការ។ អង្គភាពនិងបុគ្គលដទៃទៀត ដែលបានដឹងពីបទល្មើសពុករលួយទាំងឡាយណាដែលមានចែងក្នុងច្បាប់នេះ និងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ត្រូវប្តឹងទៅអង្គភាព ឬការិយាល័យរាជធានីខេត្ត ប្រឆាំងអំពើពុករលួយអំពីរឿងហេតុនៃបទល្មើសទាំងនេះ"។

## ខ.៤ - ការទូទាត់ និងការបើកផ្តល់

• គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ ត្រូវគោរពទៅតាមនីតិវិធី និងបទប្បញ្ញត្តិស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ និងការគ្រប់គ្រងចំណាយសាធារណៈ ជាពិសេស ត្រូវរៀបចំសំណើសុំធ្វើការទូទាត់ទៅតាមលំដាប់លំដោយនៃកម្មវិធីចំណាយប្រចាំខែឲ្យបានទៀងទាត់។

• មិនត្រូវអនុញ្ញាតឲ្យមានការលើកលែងគោលការណ៍នៃបរិបថចំណាយ ការសន្យាចំណាយ ការជម្រះបញ្ជី ការធ្វើអាណត្តិបើកប្រាក់ និងការទូទាត់ លើកលែងតែមានករណីដែលរាជរដ្ឋាភិបាលសម្រេចដោយឡែក។

• ត្រូវធ្វើការទូទាត់ និងបញ្ចេញអាណត្តិបើកប្រាក់ទៅតាមកម្មវិធីចំណាយដែលបានកំណត់។

• មិនត្រូវអនុវត្តចំណាយ និងមិនត្រូវទូទាត់ជូនចំពោះចំណាយដែលគ្មានលិខិតយុត្តិការគ្រប់គ្រាន់។

• មិនត្រូវបោះផ្សាយអាណត្តិបើកប្រាក់ ប្រសិនបើលិខិតយុត្តិការផ្គូរការមានលក្ខណៈមិនគ្រប់គ្រាន់។

• រដ្ឋទេយ្យបុរេប្រទានមានពីរប្រភេទគឺ រដ្ឋទេយ្យបុរេប្រទានថវិកាមិនមែនកម្មវិធី ដែលមានទឹកប្រាក់នៃជុំបង្វិល១ភាគ៨ លើ៣០%នៃឥណទានសរុប លើជំពូកមួយចំនួនដែលមានតម្រូវការចំណាយតាមរយៈរដ្ឋទេយ្យបុរេប្រទាន និងរដ្ឋទេយ្យបុរេប្រទានថវិកាកម្មវិធី ដែលមានទឹកប្រាក់នៃជុំបង្វិល១ភាគ៤ នៃឥណទានសរុបលើជំពូកមួយចំនួនដែលមានតម្រូវការចំណាយតាមរយៈរដ្ឋទេយ្យបុរេប្រទាន ក្រោយពីបានដកចេញរួចហើយនូវឥណទានដែលទុកសម្រាប់ចំណាយតាមនីតិវិធីទូទាត់ត្រង់។ ទោះជារដ្ឋទេយ្យបុរេប្រទានថវិកាមិនមែនកម្មវិធី ឬរដ្ឋទេយ្យបុរេប្រទានថវិកាកម្មវិធីក៏ដោយ ចំនួនលើកនៃការទូទាត់អាចអនុញ្ញាតឲ្យធ្វើបានលើសពីចំនួនជុំបង្វិល អាស្រ័យទៅតាមចំណាយជាក់ស្តែងដែលបានអនុវត្ត និងត្រូវសុំបំពេញបេឡារដ្ឋទេយ្យបុរេប្រទានឡើងវិញ ដើម្បីជៀសវាងការយឺតយ៉ាវក្នុងការទូទាត់ផង និងដើម្បីកុំឲ្យស្ទះការងារផង។ រាល់ការសុំទូទាត់ និងសុំបំពេញបេឡារដ្ឋទេយ្យបុរេប្រទានត្រូវមានលិខិតយុត្តិការគ្រប់គ្រាន់ និងអនុវត្តទៅតាមតារាងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងស្តីពីការបង្កើតរដ្ឋទេយ្យបុរេប្រទាន។ ជាមួយគ្នានេះដែរ គ្រប់ក្រសួង ស្ថាប័នត្រូវពង្រឹងការអនុវត្តឲ្យបានម៉ឺងម៉ាត់នូវប្រកាសលេខ១០១៤ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ស្ដីពីការចំណាយតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន ជាពិសេស ពាក់ព័ន្ធនឹងមុខសញ្ញាចំណាយតាមរយៈរដ្ឋទេយ្យបុរេប្រទាន និងហាមដាច់ខាតការបំបែកប័ណ្ណចំណាយទៅតាមទីកន្លែង(គោលដៅចំណាយ) ពេលវេលា ទឹកប្រាក់ចំណាយ និងសមាសធាតុនៃមុខសញ្ញាចំណាយក្នុងគោលបំណងគេចវេះការអនុវត្តនីតិវិធីលទ្ធកម្ម ឬការប្រើប្រាស់រដ្ឋទេយ្យបុរេប្រទានជំនួសការអនុវត្តនីតិវិធីលទ្ធកម្ម។ ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងពិនិត្យលទ្ធភាពកែសម្រួល និងធ្វើបច្ចុប្បន្នភាពប្រកាសខាងលើនេះ ដើម្បីសម្រួលដល់ការអនុវត្តឲ្យកាន់តែមានប្រសិទ្ធភាពស្របតាមស្ថានភាពជាក់ស្តែង។

- ការផ្តល់ថវិកាបុរេប្រទានត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិ គោលការណ៍ និងនីតិវិធីដែលមានចែងនៅក្នុងអនុក្រឹត្យលេខ១៥៥ អនក្រ បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការផ្តល់ប្រាក់បុរេប្រទានសម្រាប់ចំណាយថវិកាចរន្តនិងចំណាយថវិកាវិនិយោគសាធារណៈ។

- ទន្ទឹមនឹងនេះ ចំពោះការអនុវត្តការកាត់ទុកជាមុន លើប្រាក់ចំណូលដែលប្រមូលបានពីការផ្តល់សេវាសាធារណៈដែលអនុវត្តដោយក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត សម្រាប់ចំណាយលើប្រាក់រង្វាន់លើកទឹកចិត្តជូនមន្ត្រី និងដើម្បីពង្រឹងយន្តការប្រមូលចំណូល ត្រូវបានចាត់ទុកថាជាថវិកាបុរេប្រទានដែលបានផ្តល់ដោយថវិកាជាតិ។ ថវិកាកាត់ទុកនេះ ត្រូវធ្វើការទូទាត់ និងកត់ត្រាឆ្លុះបញ្ចាំងទាំងចំណូល និងចំណាយនៅក្នុងកិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិរបស់សាមីក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ដោយត្រូវអនុវត្តតាមនីតិវិធីទូទាត់ថវិកាបុរេប្រទានដូចខាងក្រោម៖

១. ***ផ្នែកចំណូលៈ*** ត្រូវធ្វើសលាកបត្រចំណូលថវិកាជាតិ ទៅតាមចំនួនទឹកប្រាក់ជាក់ស្តែងដែលត្រូវបានកាត់ទុក ហើយត្រូវអនុវត្តតាមគោលការណ៍ និងនីតិវិធីដូចខាងក្រោម៖

- ចំពោះរដ្ឋបាលកណ្តាល ត្រូវរៀបចំនិងបញ្ជូនសលាកបត្រចំណូលថវិកាជាតិមកនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល និងតារាងស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកបត្រ។

- ចំពោះមន្ទីរជំនាញរាជធានី ខេត្ត ត្រូវរៀបចំនិងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល និងតារាងស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។

២. **ផ្នែកចំណាយៈ** ត្រូវធ្វើអាណត្តិបើកប្រាក់ទៅតាមចំនួនទឹកប្រាក់ជាក់ស្តែងដែលបានកាត់ទុក និងដូចដែលបានចុះនៅក្នុងសលាកបត្រចំណូលថវិកាជាតិ។

- ការចេញអាណត្តិទូទាត់ត្រូវធ្វើឡើងក្រោយពីការប្រគល់ទទួល និងឲ្យស្របទៅតាមលក្ខខណ្ឌទូទាត់ក្នុងកិច្ចសន្យា។

១៣- ទន្ទឹមនឹងការអនុវត្តចំណាយទៅតាមកម្មវិធីចំណាយ ដំណើរការទូទាត់អាណត្តិបើកប្រាក់ត្រូវផ្ដល់អាទិភាពទៅលើចំណាយចាំបាច់ជាប្រចាំមានដូចជាប្រាក់បៀវត្ស ប្រាក់អាហារូបករណ៍ ប្រាក់ឧបត្ថម្ភតាមគោលនយោបាយសង្គមកិច្ច ប្រាក់បេឡាអ្នកជំងឺ ការប្រាក់សងបំណុល ទឹក ភ្លើង ទូរស័ព្ទ ភាគទានឲ្យអង្គការអន្តរជាតិនានា និងចំណាយបដិភាគរួមចំណែកជាមួយការវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស និងបន្ទាប់មកត្រូវផ្អែកលើការទូទាត់ដែលមានចែងក្នុងកិច្ចសន្យាលទ្ធកម្មសាធារណៈ។ ទន្ទឹមនឹងនេះ គ្រប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវបង្កើនការសន្សំសំចៃកម្រិតខ្ពស់ ពិសេសលើចំណាយរដ្ឋបាល ដូចជា ប្រេងឥន្ធនៈ សម្ភារៈការិយាល័យ អគ្គិសនី ទឹក ទូរស័ព្ទ ព្រមទាំងចំណាយរដ្ឋបាលផ្សេងៗ ដោយបង្កើនការគ្រប់គ្រងចំណាយឲ្យកាន់តែមានភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ ព្រមទាំងធ្វើអាទិភាពកម្មឡើងវិញក្នុងករណីចាំបាច់ដើម្បីត្រៀមកាត់បន្ថយចំណាយដើម្បីរួមចំណែករក្សាតុល្យភាពថវិកា ស្ថិរភាពថ្លៃ ស្ថិរភាពហិរញ្ញវត្ថុសាធារណៈ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។

១៤- ដើម្បីឲ្យការអនុវត្តចំណាយថវិកាថ្នាក់ជាតិប្រព្រឹត្តទៅបានទាន់ពេលវេលា និងជៀសវាងការចំណាយតិចនៅដើមឆ្នាំ ហើយទៅប្រមូលផ្ដុំចំណាយច្រើននៅចុងឆ្នាំ និងម្យ៉ាងវិញទៀតដើម្បីរក្សាតុល្យភាពថវិកាឲ្យបានរឹងមាំផងនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលឲ្យដំណើរការអនុវត្តនីតិវិធីចំណាយ ដូចជាការស្នើសុំធានាចំណាយ និងអនុវត្តវិធីសាស្ត្រលទ្ធកម្មសាធារណៈដូចតទៅ៖

- រដ្ឋមន្ត្រីដែលជាអាណាប័កដើមខ្សែត្រូវប្រញាប់ប្រញាល់ធ្វើប្រកាសស្ដីពីការតែងតាំងអាណាប័កផ្ទេរសិទ្ធិ និងការផ្ទេរឥណទានថវិកាជូនគណៈអភិបាលរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលដើម្បីឲ្យមន្ទីរជំនាញតាមរាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលអាចអនុវត្តនីតិវិធីចំណាយបានទាន់ពេលវេលា។

- ចំណាយថវិកាថ្នាក់ជាតិក្នុងការទិញសម្ភារៈ ជួលសេវា ជួសជុល និងសាងសង់ ត្រូវតែអនុវត្តឲ្យបានម៉ឺងម៉ាត់តាមគោលការណ៍ និងនីតិវិធីលទ្ធកម្មសាធារណៈ។ ចំពោះការអនុវត្តនីតិវិធីដេញថ្លៃជាសាធារណៈ ត្រូវប្រញាប់ប្រញាល់លើកសំណើសុំគោលការណ៍ធានាចំណាយឲ្យបានទាន់ពេលវេលាមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ឲ្យបាននៅដើមឆ្នាំ និងដើមឆមាស ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់អនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ។ កន្លងមកសាមីក្រសួងស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តមានការយឺតយ៉ាវក្នុងការស្នើសុំធានាចំណាយដែលជាហេតុបណ្ដាលឲ្យការងារលទ្ធកម្មត្រូវអូសបន្លាយ ហើយការងារទូទាត់ត្រូវពន្យារដល់ចុងឆ្នាំនាំឲ្យចំណាយកើនឡើងគំហុកនៅចុងឆ្នាំ។ សូមបញ្ជាក់ថា ការស្នើសុំធានាចំណាយស្រមាប់អនុវត្តនីតិវិធីលទ្ធកម្មសាធារណៈមិនទាក់ទងដល់កម្មវិធីចំណាយទេ គឺទាក់ទងតែឥណទានថវិកាដែលបានកំណត់នៅក្នុងសៀវភៅថវិកាតែប៉ុណ្ណោះ ប៉ុន្តែកម្មវិធីចំណាយត្រូវតែជាក់ស្តែង និងសុក្រឹត ព្រោះវាជាមូលដ្ឋានសម្រាប់ការរៀបចំផែនការសាច់ប្រាក់សម្រាប់ការទូទាត់។

## ២.៥ - ការអនុវត្តប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ

**១៥**- ចំពោះចំនួនក្របខ័ណ្ឌ និងប្រាក់បៀវត្សរបស់មន្ត្រីរាជការ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ត្រូវតែពិនិត្យអនុវត្តទៅតាមតារាងបៀវត្សដោយប្រព័ន្ធព័ត៌មានវិទ្យា ដែលចេញដោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងរាល់ក្របខ័ណ្ឌគតិយុត្តដែលនៅមានជាធរមាន ពិសេសអនុក្រឹត្យ សារាចរណែនាំ និងសេចក្តីជូនដំណឹងរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការជ្រើសរើសមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត ការត្រួតពិនិត្យឡើងវិញនូវចំនួន និងការគ្រប់គ្រងមន្ត្រីរាជការ និងការកែសម្រួលប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗជាដើម។ ក្នុងករណីមានការផ្ទេរមន្ត្រីរាជការពីក្រសួង ស្ថាប័នមួយទៅក្រសួង ស្ថាប័នមួយទៀតនៅក្នុងឆ្នាំ សាមីខ្លួនត្រូវបន្តទទួលបៀវត្សនៅក្រសួង ស្ថាប័នដើមរហូតដល់ដំណាច់ឆ្នាំ ហើយត្រូវធ្វើការផ្ទេរ និងគ្រោងបៀវត្សនៅក្រសួង ស្ថាប័នដែលបានផ្ទេរចូលឲ្យទាន់ពេលនៅឆ្នាំបន្ទាប់។ ដើម្បីឲ្យការប្រើប្រាស់ប្រាក់កម្រៃសម្រាប់មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែតមានសង្គតិភាព និងឯកភាពគ្នានៅគ្រប់ក្រសួង ស្ថាប័នត្រូវអនុវត្តឲ្យបានម៉ឹងម៉ាត់តាមសារាចរលេខ០០១ សហវ, ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ស្តីពីការប្រើប្រាស់ និងការផ្តល់ប្រាក់កម្រៃសម្រាប់មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត។ ក្រសួង ស្ថាប័នសាមីត្រូវសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុន លើការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត មុននឹងស្នើសុំទិដ្ឋាការពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

## ២.៦ - ការធ្វើចលនាឥណទានថវិកា

**១៦**- ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ត្រូវប្រើប្រាស់ឥណទានថវិការបស់ខ្លួនទៅតាមប្រកាសស្តីពីការបែងចែកចំណាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដូចមានលម្អិតនៅក្នុងសៀវភៅថវិកា។ នៅដើមត្រីមាសទី៣ ក្រោយពីការអនុវត្តត្រីមាសទី២ចប់សព្វគ្រប់មក ក្នុងករណីដែលមានខ្ទង់ចំណាយថវិកាណាមួយមានឥណទានមិនគ្រប់គ្រាន់តែចាំបាច់ត្រូវចំណាយ ត្រូវធ្វើសំណើសុំនិយ័តភាពមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យ និងសម្រេចជាមុនសិនទើបអាចលើកសំណើសុំខ្ទង់ចំណាយនោះបាន។ ដើម្បីសម្រួលដល់ការអនុវត្តចំណាយថវិកាកម្មវិធី ត្រូវបានធ្វើប្រតិភូកម្មសិទ្ធិអំណាចដល់អាណាប័កដើមខ្សែដែលជាប្រធានក្រសួង ស្ថាប័ន ក្នុងការធ្វើនិយ័តភាពពីអនុគណនីមួយទៅអនុគណនីមួយទៀតនៅក្នុងគណនីតែមួយ។ ការធ្វើនិយ័តភាពនេះ ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួង ស្ថាប័នសាមី ដោយមានចុះហត្ថលេខារបស់រដ្ឋមន្ត្រី ឬប្រធានស្ថាប័នដែលជាអាណាប័កដើមខ្សែ។ បើក្រសួង ស្ថាប័ន មានសំណូមពរផ្តល់ឥណទានបន្ថែមសម្រាប់ផ្តល់ទៅឲ្យមន្ទីរជំនាញរាជធានី ខេត្តរបស់ខ្លួន គឺការផ្តល់ឥណទានបន្ថែមនោះ ត្រូវធ្វើឡើងដោយប្រកាសផ្ទេរឥណទានរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីឲ្យអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត (អាណាប័កតាមការប្រទានសិទ្ធិ) ដែលជាខ្សែទទឹង និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចតាមដានការប្រើប្រាស់ឥណទានថវិកាបន្ថែមទាំងនោះបាន។ ការធ្វើនិយ័តភាពចេញពីថវិកាកម្មវិធីទៅថវិកាមិនមែនកម្មវិធី ឬការធ្វើនិយ័តភាពពីកម្មវិធីមួយទៅកម្មវិធីមួយទៀតត្រូវស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយអាចអនុញ្ញាតឲ្យបានលុះត្រាតែក្រសួង ស្ថាប័នមានរបាយការណ៍តាមដានការអនុវត្តកម្មវិធីនីមួយៗយ៉ាងច្បាស់លាស់ ពិសេសប្រធានកម្មវិធី

និងប្រធានស្ថាប័ន ត្រូវបញ្ជាក់ថាការធ្វើនិយ័តភាពនេះនឹងមិនប៉ះពាល់ដល់ការសម្រេចបានតាមគោលដៅនៃសូចនាករ និងគោលបំណងរបស់ចង្កោមសកម្មភាព អនុកម្មវិធី កម្មវិធី ក៏ដូចជាទិសដៅគោលនយោបាយរបស់ក្រសួង ស្ថាប័នឡើយ។

## III. ការត្រួតពិនិត្យ តាមដានការអនុវត្តថវិកា និងការធ្វើរបាយការណ៍

**១៧**-ពង្រឹងតួនាទីរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់បណ្តាក្រសួង ស្ថាប័ននានា និងអគ្គាធិការដ្ឋានរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងការត្រួតពិនិត្យការអនុវត្តថវិកាជាតិ ជាពិសេសការត្រួតពិនិត្យជាក់ស្តែងរាល់ការប្រមូលចំណូល និងការអនុវត្តចំណាយថវិកាជាតិ ដោយវាយតម្លៃការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។

**១៨**-ដើម្បីបង្កើនគណនេយ្យភាព និងការទទួលខុសត្រូវចំពោះលទ្ធផលនៃចំណាយសាធារណៈ ជាពិសេស ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តថវិកា គ្រប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ត្រូវធ្វើការតាមដានការអនុវត្តថវិការបស់ខ្លួនជាប្រចាំ និងធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(នាយកដ្ឋានថវិកា និងនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ)ឲ្យបានទៀងទាត់ទៅតាមគំរូដែលបានផ្ញើជូន និងទៅតាមកាលបរិច្ឆេទដូចខាងក្រោម៖

- របាយការណ៍ប្រចាំខែ ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១០នៃខែបន្ទាប់។
- របាយការណ៍ប្រចាំត្រីមាសត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥នៃខែនៅដើមត្រីមាសបន្ទាប់។
- របាយការណ៍ឆមាសទី១ ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែមិថុនា។
- របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤។

## IV. វិធានការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

**១៩**-គ្រប់ក្រសួង ស្ថាប័នដែលជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវធ្វើបញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំនីមួយៗរួចរាល់ និងផ្ញើមកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ(នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)យ៉ាងយូរត្រឹមចុងត្រីមាសទី១នៃឆ្នាំបន្ទាប់។

**២០**-អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះមុខរាជរដ្ឋាភិបាលក្នុងករណីមិនអាចសម្រេចបាននូវការធ្វើបញ្ជីសារពើភ័ណ្ឌតាមពេលវេលាកំណត់ និងពុំបានចុះបញ្ជីអស់គ្រប់ចំនួននូវទ្រព្យសម្បត្តិរដ្ឋចូលក្នុងបញ្ជីសារពើភ័ណ្ឌ។

## V. វិធានការរក្សាតុល្យភាព និងប្រសិទ្ធភាពថវិកា

**២១**- នៅពេលដែលពិនិត្យឃើញថាស្ថានភាពនៃការអនុវត្តថវិកានឹងមិនអាចសម្រេចបានទៅតាមការគ្រោងទុក ដើម្បីរក្សាតុល្យភាព និងប្រសិទ្ធភាពថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានវិធានការដូចខាងក្រោម៖

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងសហការជាមួយក្រសួងផែនការ និងធនាគារជាតិនៃកម្ពុជា ដើម្បីបន្តបង្កើនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំនូវស្ថានភាពហិរញ្ញវត្ថុនិងសេដ្ឋកិច្ច ក្នុង

គោលបំណងកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ជាអវិជ្ជមានពីខាងក្រៅ និងរក្សាឲ្យបាននូវស្ថិរភាពហិរញ្ញវត្ថុនិងសេដ្ឋកិច្ចនៅកម្ពុជា។

- ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការតាមដានការអនុវត្តថវិកា និងសកម្មភាពការងាររបស់ខ្លួនជាប្រចាំ និងអនុវត្តប្រកបដោយភាពទន់ភ្លន់ទៅតាមសភាពការណ៍ហិរញ្ញវត្ថុនិងសេដ្ឋកិច្ចដែលបាននិងកំពុងប្រែប្រួលស្ទើរតែមិនអាចព្យាករបានប្រកបដោយលក្ខណៈសកម្មគ្រប់គ្រង។
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងធ្វើការត្រួតពិនិត្យ លើការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ ដើម្បីជាមូលដ្ឋានក្នុងការធ្វើថវិកាកែតម្រូវក្នុងករណីចាំបាច់។
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនអនុញ្ញាតឲ្យមានការបោះផ្សាយអាណត្តិតម្កល់ទុកសម្រាប់ចំណាយនៅឆ្នាំបន្ទាប់ឡើយ។

២២-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់នឹងរួមសហការក្នុងការអនុវត្តថវិកាឆ្នាំ២០១៣របស់យើងឲ្យសម្រេចបានតាមការគ្រោងទុកដើម្បីបម្រើឲ្យការអនុវត្តប្រកបដោយជោគជ័យនូវ "**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២**" ក៏ដូចជា "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣**" ដើម្បី *ជំរុញកំណើន បង្កើតការងារ ធានាសមធម៌* និង*ប្រសិទ្ធភាព* នៅកម្ពុជា ដែលជា "**របៀបវារៈគោលនយោបាយ សង្គម-សេដ្ឋកិច្ច**" នៃ "**កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤**"។ ៚

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់រាជធានី ខេត្ត
"ដើម្បីអនុវត្ត"
-រាជកិច្ច
"ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ